ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

នាយកដ្ឋានសវនកម្មផ្ទៃក្នុង

# របាយការណ៍សវនកម្ម
# ប្រចាំត្រីមាសទី ១ ឆ្នាំ ២០២០

៚៙៚

- ឯកសារសង្ខេបៈ

| | |
|---|---|
| នាយកដ្ឋានសវនកម្មផ្ទៃក្នុង | ក្រសួងអភិវឌ្ឍន៍ជនបទ |
| ចំណងជើង | របាយការណ៍សវនកម្មប្រចាំត្រីមាសទី ១ ឆ្នាំ ២០២០ |
| ប្រធានប្រតិភូ | លោក ពេជ្រ សេដ្ឋា |
| អ្នកត្រួតពិនិត្យ | ថ្នាក់ដឹកនាំ និងមន្ត្រីនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| សវនដ្ឋាន | មន្ទីរអភិវឌ្ឍន៍ជនបទចំនួន ០៤ រាជធានី-ខេត្ត |
| ទីកន្លែងឯកសាររឹង | ការិយាល័យរដ្ឋបាល និងបុគ្គលិក នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ទីកន្លែងឯកសារទន់ | ការិយាល័យរដ្ឋបាល និងបុគ្គលិក |

- ការបែងចែកឯកសារៈ

| ឈ្មោះ | មុខតំណែង/តួនាទី | កន្លែងទទួល |
|---|---|---|
| ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន | រដ្ឋមន្ត្រី | ក្រសួងអភិវឌ្ឍន៍ជនបទ |
| លោកជំទាវ សោម គីមសួគ៌ | អគ្គសវនករ | អាជ្ញាធរសវនកម្មជាតិ |
| លោកប្រធានមន្ទីរ | ប្រធានមន្ទីរ | មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត |

# មាតិកា

ទំព័រ

ផ្នែកទី I: ខ្លឹមសារសង្ខេប........................................................................ ៤
១. សាវតារ ........................................................................................ ៤
២. ហានិភ័យគន្លឹះ .................................................................................. ៤
៣. វិសាលភាពសវនកម្ម.............................................................................. ៤
៤. គោលបំណងសវនកម្ម និងការត្រួតពិនិត្យ............................................... ៤
៥. អភិក្រមសវនកម្ម..................................................................................... ៤
៦. សង្ខេបលទ្ធផលគន្លឹះ.............................................................................. ៥
៧. សេចក្ដីសន្និដ្ឋាន........................................................................................ ៥
៨. វិធានការកែលម្អ....................................................................................... ៥
៩. អំណរគុណ................................................................................................. ៥
ផ្នែកទី II: លទ្ធផលសវនកម្មលម្អិត............................................................... ៦
១. ប្រតិភូសវនកម្មផ្ទៃក្នុង និងខណៈគោលសំខាន់ៗ........................................ ៦
២. ទិដ្ឋភាពរួមសវនកម្មផ្ទៃក្នុង................................................................... ៦
៣. ការពិនិត្យការគ្រប់គ្រងផ្ទៃក្នុង.................................................................. ៧
៤. ព័ត៌មានអំពីសវនដ្ឋាន............................................................................... ៧
៥. លទ្ធផលសវនកម្ម....................................................................................... ៧
ផ្នែកប្រសិទ្ធភាពប្រតិបត្តិការ........................................................................ ៧
ក. ប្រព័ន្ធត្រួតពិនិត្យបំពេញមុខងារមិនទាន់ពេញលេញ.......................... ៧
ផ្នែកព័ត៌មានហិរញ្ញវត្ថុ............................................................................... ៨
ខ. មានភាពខ្វះចន្លោះក្នុងការអនុវត្តនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ.................. ៨
ផ្នែកអនុលោមភាព..................................................................................... ៩
គ. ការអនុវត្តនីតិវិធីរដ្ឋបាលមិនទាន់បានគ្រប់ជ្រុងជ្រោយ......................... ៩
៦. សេចក្ដីសន្និដ្ឋានរួម.................................................................................. ១០
៧. ផែនការសកម្មភាពកែលម្អ ....................................................................... ១០

# ផ្នែកទី I: ខ្លឹមសារសង្ខេប

## ១. សាវតារ

ការធ្វើសវនកម្មនៅមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត សម្រាប់ការិយបរិច្ឆេទ ២០១៩ ជាផ្នែកមួយនៃផែនការប្រចាំឆ្នាំរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលទទួលបានការយល់ព្រមពី **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** ក្រសួងអភិវឌ្ឍន៍ជនបទ។

## ២. ហានិភ័យគន្លឹះ

ការធ្វើសវនកម្មផ្ទៃក្នុងនៅមន្ទីរអភិវឌ្ឍន៍ជនបទទាំង ០៤ ខេត្ត សម្រាប់ការិយបរិច្ឆេទ ២០១៩ សវនករផ្ទៃក្នុងអាចកំណត់បាននូវហានិភ័យមួយចំនួន ក្នុងនោះហានិភ័យគន្លឹះរួមមាន៖

- ខ្វះខាតក្នុងការត្រួតពិនិត្យតាមដានលទ្ធផលសម្រេច
- ប្រព័ន្ធត្រួតពិនិត្យហិរញ្ញវត្ថុមិនទាន់បានរៀបចំពេញលេញ
- ភាពខ្វះខាតលើការរៀបចំប្រព័ន្ធត្រួតពិនិត្យរដ្ឋបាល

## ៣. វិសាលភាពសវនកម្ម

ការធ្វើសវនកម្មផ្ទៃក្នុង គឺឆ្ពោះទៅលើសកម្មភាពគ្រប់គ្រង ដឹកនាំរបស់គណៈគ្រប់គ្រងអង្គភាព និងប្រតិបត្តិការទាំងឡាយ សម្រាប់ការិយបរិច្ឆេទ ២០១៩។ ការប្រមូលព័ត៌មានសវនកម្ម និងការធ្វើតេស្តសវនកម្មត្រូវបានប្រព្រឹត្តទៅនៅការិយាល័យរដ្ឋបាល ការិយាល័យគណនេយ្យ ការិយាល័យផ្គត់ផ្គង់ទឹកជនបទ និងការិយាល័យសុខភាពជនបទនៅតាមមន្ទីរអភិវឌ្ឍន៍ជនបទទាំង ០៤ ខេត្ត។

## ៤. គោលបំណងសវនកម្ម និងការត្រួតពិនិត្យ

គោលបំណងសវនកម្មរួមគឺវាយតម្លៃនិងធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃដំណើរការគ្រប់គ្រងហានិភ័យ ដំណើរការត្រួតពិនិត្យ និងដំណើរការអភិបាលកិច្ចក្នុងដែនសវនកម្មដែលស្ថិតក្នុងវិសាលភាពសវនកម្ម។

ជារួមការងារសវនកម្មផ្ទៃក្នុងផ្តោតទៅលើការបញ្ជាក់ថា ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងអាចផ្តល់នូវការធានាសមហេតុផលមួយ សំដៅសម្រេចបាននូវគោលបំណងដូចខាងក្រោម៖

-គោលបំណងប្រតិបត្តិការ : ការសម្រេចបានប្រកបដោយប្រសិទ្ធភាពនៃគោលបំណងធុរកិច្ច។

-គោលបំណងព័ត៌មាន : ភាពជឿទុកចិត្ត និងភាពពេញលេញនៃព័ត៌មានផ្នែកហិរញ្ញវត្ថុ ដែលប្រើប្រាស់ដោយថ្នាក់ដឹកនាំ។

-គោលបំណងអនុលោមភាព៖ អនុលោមជាមួយច្បាប់ បញ្ញត្តិ គោលការណ៍ នីតិវិធីជាធរមាន។

## ៥. អភិក្រមសវនកម្ម

អភិក្រមសវនកម្មផ្តោតលើដំណើរការមានហានិភ័យ ត្រូវបានប្រើប្រាស់នៅក្នុងការងារសវនកម្មនេះ។ អភិក្រមសវនកម្មរាប់បញ្ចូលៈ

-កំណត់ត្រានូវប្រព័ន្ធគ្រប់គ្រង (កុងត្រូល) ផ្ទៃក្នុងតាមរយៈការត្រួតពិនិត្យ ឯកសារពាក់ព័ន្ធ និងសម្ភាសន៍មន្ត្រី

-ការកំណត់នូវកុងត្រូលគន្លឹះ និងធ្វើការប្រៀបធៀបជាមួយកុងត្រូលដែលបានរំពឹងទុក

-តេស្តសវនកម្មនូវប្រសិទ្ធភាពប្រតិបត្តិការនៃកុងត្រូល

-ពិនិត្យតំបន់គោលដៅជាក់ស្តែង។

តាមរយៈការងារសវនកម្ម ប្រតិភូសវនកម្មបានសហការកំណត់ការរំពឹងទុករួមជាមួយថ្នាក់ដឹកនាំ និងគ្រប់គ្រងសវនដ្ឋាន។

### ៦. សង្ខេបលទ្ធផលគន្លឹះ

ប្រតិភូសវនកម្មផ្ទៃក្នុងបានកត់សម្គាល់ឃើញនូវចំណុចខ្វះចន្លោះមួយចំនួនដូចខាងក្រោមៈ

-ការសាងសង់មិនទាន់បានបញ្ចប់ទៅតាមផែនការដែលបានគ្រោងទុក

-ប្រព័ន្ធត្រួតពិនិត្យហិរញ្ញវត្ថុ បំពេញមុខងារមិនទាន់ពេញលេញល្អ

-ការរៀបចំ និងគ្រប់គ្រងការងាររដ្ឋបាល មិនទាន់មានប្រសិទ្ធិភាពខ្ពស់។

### ៧. សេចក្ដីសន្និដ្ឋាន

មន្ទីរអភិវឌ្ឍន៍ជនបទទាំង ០៤ ខេត្ត បានបំពេញការងារទៅតាមតួនាទីភារកិច្ចដោយស្មារតីទទួលខុសត្រូវខ្ពស់ និងស្របទៅតាមច្បាប់ បទប្បញ្ញត្តិ គោលការណ៍ណែនាំដែលបានកំណត់ ដែលនាំឲ្យសម្រេចបានលទ្ធផលគួរជាទីមោទនៈ។

ទោះជាយ៉ាងណាក៏នៅមានចំណុចខ្វះខាតលើផ្នែកប្រតិបត្តិការ ដែលអាចប៉ះពាល់ទៅដល់ស័ក្តិសិទ្ធភាពនៃផលសម្រេច ថ្វីបើនៅពេលនេះ វាមិនបានធ្វើឲ្យរាំងស្ទះដល់ដំណើរការរបស់អង្គភាពទាំងមូលក៏ដោយ។ ម្យ៉ាងវិញទៀត ប្រព័ន្ធត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រងរដ្ឋបាលក៏បំពេញមុខងារមិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយ។

### ៨. វិធានការកែលម្អ

អនុសាសន៍ដែលផ្ដល់ជូន ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវការអនុវត្តដំណើរការការងារ និងការគ្រប់គ្រងផ្ទៃក្នុងរបស់សវនដ្ឋានត្រូវបានដាក់បញ្ចូលទៅក្នុងលទ្ធផលលម្អិត(ផ្នែកII) ។ អនុសាសន៍ និងការរកឃើញមួយចំនួន បានឯកភាពគ្នាជាមួយថ្នាក់ដឹកនាំជាលាយលក្ខអក្សរ។ លទ្ធផលលម្អិត(ផ្នែកII) ក៏មានរំលេចនូវការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងចំពោះអនុសាសន៍សវនកម្ម និងការរកឃើញផងដែរ។

វិធានការកែលម្អរបស់ថ្នាក់ដឹកនាំ គឺមានបង្ហាញក្នុងផែនការសកម្មភាពកែលម្អចែងក្នុងឧបសម្ព័ន្ធទី២ (ឧបសម្ព័ន្ធទី២ រក្សាទុកនៅនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងអភិវឌ្ឍន៍ជនបទ) ។ ផែនការសកម្មភាពកែលម្អមានបញ្ចូលលម្អិត នូវសកម្មភាពដែលសវនដ្ឋានបានឯកភាពទទួលយកដើម្បីអនុវត្តតាមអនុសាសន៍ទាំងនោះ។ អនុសាសន៍នីមួយៗត្រូវបានរៀបចំតាមចំណាត់ថ្នាក់ ដើម្បីបង្ហាញនូវកម្រិតហានិភ័យដល់ថ្នាក់ដឹកនាំ ប្រសិនបើអនុសាសន៍នោះមិនត្រូវបានអនុវត្ត។

នាពេលអនាគត នាយកដ្ឋានសវនកម្មផ្ទៃក្នុងនឹងពិនិត្យឡើងវិញលើវឌ្ឍនភាពនៃការអនុវត្តតាមអនុសាសន៍ដែលបានផ្ដល់ជូនដែលជាផ្នែកមួយនៃនីតិវិធីតាមដានអនុសាសន៍សវនកម្មគ្រាមុន។

### ៩. អំណរគុណ

ក្នុងនាមប្រតិភូសវនកម្មផ្ទៃក្នុង ខ្ញុំសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីភ្នំពេញទាំងអស់ ដែលបានរួមចំណែកសហការតាមគ្រប់សកម្មភាពដែលសវនករត្រូវការ និងអរគុណទៅដល់ **ឯកឧត្តមអនុរដ្ឋលេខាធិការ និងរដ្ឋលេខាធិការ** ទទួលបន្ទុកក្នុងការសម្របសម្រួល និងផ្ដល់នូវមតិបំពេញបន្ថែមក្នុងការអនុវត្តការងាររបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ជាពិសេសសូម

សម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី** ដែលតែងតែជំរុញគាំទ្រទាំងសម្ភារ និងស្មារតី ព្រមទាំងអនុសាសន៍ដឹកនាំដ៏មានតម្លៃសំដៅលើកកម្ពស់មុខងារសវនកម្មផ្ទៃក្នុងឲ្យមានដំណើរការប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។

## ផ្នែកទី II: លទ្ធផលសវនកម្មលម្អិត

### ១ .ប្រតិភូសវនកម្មផ្ទៃក្នុង និងខណៈគោលសំខាន់ៗ

១.១ ប្រតិភូសវនកម្មផ្ទៃក្នុង

នៅក្នុងការងារសវនកម្មនេះ មានសមាសភាពចូលរួមដូចខាងក្រោមៈ

**ក. ក្រុមទី ១**

- លោក ពេជ្រ សេដ្ឋា ប្រធានគណៈប្រតិភូ
- លោក នឹម កុល សមាជិក
- លោក ងឹម ម៉ាណូ សមាជិក
- លោក ឈឹម គឹមមុនីរដ្ឋា សមាជិក
- លោក សូ សំណាង សមាជិក

**ខ. ក្រុមទី ២**

- លោក ម៉ម សុភា ប្រធានក្រុម
- លោក លឹម សំណាង សមាជិក
- លោក ពេជ្រ វិចិត្រា សមាជិក
- លោក សូភី សារ៉ាបុត្រ សមាជិក
- លោក យ៉ាន់ បូរិន សមាជិក

១.២ ខណៈគោលសំខាន់ៗ

ខាងក្រោមគឺជាខណៈគោលសំខាន់ៗ នៅក្នុងដំណើរការសវនកម្មៈ

| | |
|---|---|
| -ការធ្វើសវនកម្មបានបញ្ចប់ | ថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០២០ |
| -សេចក្តីព្រាងលើកទី១ បានបញ្ចប់ | ថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០២០ |
| -ការឆ្លើយតបចុងក្រោយពីថ្នាក់ដឹកនាំបានទទួល | ថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០២០ |
| -របាយការណ៍ស្ថាពរ | ថ្ងៃទី ០៥ ខែមីនា ឆ្នាំ ២០២០ |

### ២.ទិដ្ឋភាពរួមសវនកម្មផ្ទៃក្នុង

គោលបំណងរួមនៃសវនកម្មផ្ទៃក្នុងគឺជួយថ្នាក់ដឹកនាំរៀបចំ និងអនុវត្តឲ្យកាន់តែល្អប្រសើរឡើងនូវដំណើរ-ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ច ។ ការត្រួតពិនិត្យផ្ទៃក្នុងត្រូវបានអនុវត្តដោយថ្នាក់ដឹកនាំ និងមន្ត្រីដទៃទៀតដើម្បីជានាឲ្យសម្រេចបាននូវគោលបំណងដូចខាងក្រោម ៖

- របាយការណ៍ហិរញ្ញវត្ថុគួរឲ្យទុកចិត្តបាន
- ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល ស័ក្តិសិទ្ធភាព
- ការអនុវត្តតាមច្បាប់ និងបទដ្ឋាននានា។

របាយការណ៍នេះរួមមានការពិនិត្យលើការតាក់តែង និងប្រតិបត្តិការនៃការត្រួតពិនិត្យផ្ទៃក្នុងដោយសវនករ នៅទីសវនកម្មអាទិភាពមួយចំនួនដែលបានឯកភាពជាមួយថ្នាក់គ្រប់គ្រងសវនដ្ឋាន។

### ៣ .ការពិនិត្យការគ្រប់គ្រងផ្ទៃក្នុង

សវនករបានវាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដោយធ្វើការពិនិត្យលើសមត្ថភាពនៃដំណើរការគ្រប់គ្រងនីមួយៗដោយផ្ទៀងផ្ទាត់ជាមួយលក្ខណៈវិនិច្ឆ័យគ្រប់គ្រងចំនួនប្រាំពីរ ក្នុងនោះមាន ការផ្តល់សិទ្ធិ ភាពពេញលេញ, ភាពត្រឹមត្រូវ, សុពលភាព, សុវត្ថិភាពរូបវន្ត, ការដោះស្រាយកំហុស និងការបែងចែកតួនាទី។

### ៤.ព័ត៌មានអំពីសវនដ្ឋាន

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តមណ្ឌលគិរី រតនគិរី កំពង់ស្ពឺ និងរាជធានីភ្នំពេញ ជាសេនាធិការរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។ មន្ទីរមានរចនាសម្ព័ន្ធចែកជា ១០ ការិយាល័យ ៖ ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ ការិយាល័យគណនេយ្យ ការិយាល័យផែនការ ការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ ការិយាល័យអភិវឌ្ឍន៍សហគមន៍ ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ការិយាល័យអភិវឌ្ឍន៍ជនជាតិភាគតិច ការិយាល័យថែទាំសុខភាពជនបទ ការិយាល័យផ្គត់ផ្គង់ទឹកជនបទ និងការិយាល័យផ្លូវជនបទ។

### ៥. លទ្ធផលសវនកម្ម

ផ្នែកប្រសិទ្ធភាពប្រតិបត្តិការ

ក.ប្រព័ន្ធត្រួតពិនិត្យបំពេញមុខងារមិនបានពេញលេញ

គោលបំណង ដើម្បីបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃផលសម្រេច។

លទ្ធផល សវនករផ្ទៃក្នុងបានពិនិត្យឃើញថា៖

ក.១ មិនទាន់បញ្ចប់ការសាងសង់អាងត្រងទឹកភ្លៀងចំនួន ២៦/៣៧អាង និងអណ្តូងស្នប់ថ្មីចំនួន ០៤/០៧អណ្តូង ទាំងស្រុងនៅឡើយទេ។

លក្ខណៈវិនិច្ឆ័យ មិនអនុលោមតាមកិច្ចសន្យាការងារ ។

ឫសគល់បញ្ហា មានភាពយឺតយ៉ាវខ្វះលើនីតិវិធីអនុវត្ត និងការចូលរួមពីសហគមន៍។

បច្ច័យ ប៉ះពាល់ដល់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃផលសម្រេចទៅតាមពេលដែលបានកំណត់។

អនុសាសន៍ មន្ទីរត្រូវចុះត្រួតពិនិត្យមើលឡើងវិញ និងជំរុញឲ្យបញ្ចប់ការសាងសង់ឲ្យបានឆាប់ទៅតាមដែលអាចធ្វើទៅបាន។

មតិឆ្លើយតបរបស់សវនដ្ឋាន សូមឯកភាពនូវចំណុចនេះ ខ្ញុំសូមសន្យាថានឹងធ្វើការកែលម្អទៅតាមអនុសាសន៍សវនកម្ម។

ការអធិប្បាយបន្ថែមរបស់សវនករ សវនដ្ឋានបានទទួលស្គាល់នូវចំណុចខ្វះខាតដែលសវនករបានរកឃើញ និងសន្យាកែលម្អឲ្យបានត្រឹមត្រូវតាមអនុសាសន៍សវនកម្មផ្ទៃក្នុង។

ក.២ មិនមានលិខិតស្នើសុំពីសហគមន៍សម្រាប់ការងារសាងសង់ស្រះសហគមន៍ចំនួន ០១ កន្លែង និងសាងសង់អណ្តូងស្នប់ចំនួន ០៥ អណ្តូង។

លក្ខណៈវិនិច្ឆ័យ មិនទាន់អនុលោមតាមបទដ្ឋានបច្ចេកទេសគម្រោង។

ឫសគល់បញ្ហា ស្មារតីយកចិត្តទុកដាក់របស់ភាគីពាក់ព័ន្ធនៅមានកម្រិត។

បច្ច័យ ប៉ះពាល់ទៅដល់គុណភាពនៃផលសម្រេច និងប្រសិទ្ធភាពនៃភាពអនុលោម។

អនុសាសន៍ គួរតែឲ្យសហគមន៍តាមមូលដ្ឋានធ្វើលិខិតស្នើសុំស្រះសហគមន៍ ឬអណ្តូងស្នប់មក មន្ទីរអភិវឌ្ឍន៍ជនបទជាមុនសិនទើបយើងលើកផែនការសម្រេច និងចុះអនុវត្ត។

មតិឆ្លើយតបរបស់សវនដ្ឋាន សូមឯកភាពនូវចំណុចនេះ ខ្ញុំសូមសន្យាថានឹងធ្វើការកែលម្អទៅតាមអនុសាសន៍របស់សវនកម្មផ្ទៃក្នុងសម្រាប់ការអនុវត្តពេលក្រោយទៀត។

ការអធិប្បាយបន្ថែមរបស់សវនករ សវនដ្ឋានបានទទួលស្គាល់នូវចំណុចខ្វះខាតដែលសវនករបានរកឃើញ និងសន្យាកែលម្អឲ្យបានត្រឹមត្រូវតាមអនុសាសន៍សវនកម្មផ្ទៃក្នុង។

ផ្នែកព័ត៌មានហិរញ្ញវត្ថុ

ខ. មានភាពខ្វះចន្លោះក្នុងការអនុវត្តនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ។

គោលបំណង ពង្រឹងគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ។

លទ្ធផល សវនករផ្ទៃក្នុងបានពិនិត្យឃើញថា៖

ខ.១ វិក្កយបត្រចំណាយមួយចំនួន មិនបានចុះថ្ងៃ ខែ ឆ្នាំ ឲ្យបានពេញលេញ ហើយបណ្ណចំណាយមួយចំនួន មិនបានចុះហត្ថលេខាពីប្រធានគណនេយ្យ។

លក្ខណៈវិនិច្ឆ័យ មិនអនុលោមតាមប្រកាសលេខ ៖ ២៧៥ សហវ.ប្រក ស្តីពី នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រង់ប្រការ ១៤ ។

ឫសគល់បញ្ហា ការត្រួតពិនិត្យឯកសារមិនបានល្អិតល្អន់។

បច្ច័យ ប៉ះពាល់ដល់ការអនុវត្តតាមប្រកាសលេខ ៖ ២៧៥ សហវ.ប្រក ស្តីពី នីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រង់ប្រការ ១៤ ៖ បានចែងថា "ការចំណាយនិងការទូទាត់ប្រាក់ រជ្ជទេយ្យបុរេប្រទានត្រូវមានសក្ខីប័ត្របញ្ជាក់ត្រឹមត្រូវ"។

អនុសាសន៍ ត្រូវចុះថ្ងៃ ខែ ឆ្នាំ ឲ្យគ្រប់ចំនួនលើវិក្កយបត្រទូទាត់ការចំណាយ និងប្រធានគណនេយ្យត្រូវចុះហត្ថលេខាលើបណ្ណចំណាយឲ្យបានត្រឹមត្រូវ។

មតិឆ្លើយតបរបស់សវនដ្ឋាន ខ្ញុំសូមឯកភាព និងទទួលស្គាល់នូវចំណុចខ្វះខាត ដែលសវនករបានរកឃើញ និងខិតខំយកចិត្តទុកដាក់ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុឲ្យបានល្អប្រសើរ ដើម្បីប្រសិទ្ធភាពនៃការប្រើប្រាស់ថវិការដ្ឋ និងចូលរួមចំណែកក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ការអធិប្បាយបន្ថែមរបស់សវនករ មន្ទីរបានទទួលស្គាល់ចំណុចខ្វះចន្លោះដែលសវនករបានរកឃើញ និងបង្ហាញនូវការយកចិត្តទុកដាក់ខ្ពស់ក្នុងការកែលម្អតាមអនុសាសន៍។

ខ.២ ការចំណាយលើការជួសជុលបន្ទប់ការិយាល័យមិនបានបញ្ជាក់អត្តសញ្ញាណ របស់អ្នកទទួលការច្បាស់លាស់។

លក្ខណៈវិនិច្ឆ័យ មិនអនុលោមតាមគោលការណ៍ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ។

ឫសគល់បញ្ហា កង្វះខាតការតាមដាន និងត្រួតពិនិត្យ។

បច្ច័យ នាំឲ្យមានភាពមិនច្បាស់លាស់ក្នុងការចំណាយរបស់មន្ទីរ។

អនុសាសន៍ ការចំណាយសម្រាប់ការជួសជុលបន្ទប់ការិយាល័យត្រូវថតចម្លងអត្តសញ្ញាណប័ណ្ណ និងលេខទូរស័ព្ទទំនាក់ទំនងឲ្យបានច្បាស់លាស់។

<u>មតិឆ្លើយតបរបស់សវនដ្ឋាន</u> ខ្ញុំសូមឯកភាព និងអនុវត្តតាមអនុសាសន៍។

<u>ការអធិប្បាយបន្ថែមរបស់សវនករ</u> មន្ទីរបានទទួលស្គាល់ចំណុចខ្វះខាតដែលសវនករបានរកឃើញ និងធ្វើការកែលម្អតាមអនុសាសន៍។

ផ្នែកអនុលោមភាព

គ. ការអនុវត្តនីតិវិធីរដ្ឋបាលមិនទាន់បានគ្រប់ជ្រុងជ្រោយ

<u>គោលបំណង</u> ដើម្បីរក្សាសុវត្ថិភាពទ្រព្យសម្បត្តិរដ្ឋ និងពង្រឹងការគ្រប់គ្រងមន្ត្រីរាជការឲ្យមានប្រសិទ្ធភាពខ្ពស់។

<u>លទ្ធផល</u> សវនករផ្ទៃក្នុងបានពិនិត្យឃើញថា៖

គ.១ លិខិតចេញ-ចូលមួយចំនួនមិនបានរក្សាទុកក្នុងក្រូណូ និងសៀវភៅចុះលេខមានការកោសលុប។

<u>លក្ខណៈវិនិច្ឆ័យ</u> មិនទាន់ឆ្លើយតបបានទៅនឹងគោលការណ៍គ្រប់គ្រងរដ្ឋបាល និងនីតិវិធីគ្រប់គ្រងរដ្ឋបាល។

<u>ឫសគល់បញ្ហា</u> ឆន្ទៈ និងស្មារតីយកចិត្តទុកដាក់របស់មន្ត្រីគ្រប់គ្រងរដ្ឋបាល ។

<u>បច្ច័យ</u> ពិបាកក្នុងការរកឯកសារ និងអាចបណ្តាលឲ្យបាត់បង់ឯកសារ។

<u>អនុសាសន៍</u> ប្រធានមន្ទីរត្រូវធ្វើការពិនិត្យមើលឡើងវិញ និងចាត់វិធានការកែលម្អ។

<u>មតិឆ្លើយតបរបស់សវនដ្ឋាន</u> ខ្ញុំសូមទទួលស្គាល់លើចំណុចអសកម្មនេះ និងអនុវត្តតាមអនុសាសន៍សវនកម្មដោយឈរលើស្មារតីទទួលខុសត្រូវ។

<u>ការអធិប្បាយបន្ថែមរបស់សវនករ</u> លោកប្រធានមន្ទីរបានទទួលស្គាល់ចំណុចនេះ និងប្តេជ្ញាកែលម្អតាមអនុសាសន៍សវនកម្ម។

គ.២ ការរៀបចំ និងការគ្រប់គ្រងបញ្ជីវត្តមានប្រចាំថ្ងៃមិនទាន់បានពេញលេញ។

<u>លក្ខណៈវិនិច្ឆ័យ</u> ការគ្រប់គ្រងវត្តមានមន្ត្រីរាជការ មិនទាន់អនុលោមពេញលេញទៅតាមគោលការណ៍ណែនាំនៃអនុក្រឹត្យលេខ ៥៦ អនក្រ.បក ស្តីពីការគ្រប់គ្រងវត្តមានរបស់មន្ត្រីរាជការ។

<u>ឫសគល់បញ្ហា</u> កង្វះខាតក្នុងការតាមដាន ត្រួតពិនិត្យ និងការយកចិត្តទុកដាក់ពីការណែនាំដែលមានចែងក្នុងអនុក្រឹត្យលេខ ៥៦ អនក្រ.បក។

<u>បច្ច័យ</u> ប្រសិទ្ធភាពនៃការគ្រប់គ្រងវត្តមានរបស់មន្ត្រីរាជការ។

<u>អនុសាសន៍</u> មន្ទីរត្រូវពង្រឹងការយកចិត្តទុកដាក់ដល់មន្ត្រីគ្រប់រូបដើម្បីអនុវត្តឲ្យបានពេញលេញអនុលោមតាមអនុក្រឹត្យលេខ ៥៦ អនក្រ.បក ដើម្បីឲ្យការគ្រប់គ្រងមន្ត្រីរាជការក្នុងមន្ទីរកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

<u>មតិឆ្លើយតបរបស់សវនដ្ឋាន</u> ខ្ញុំសូមទទួលស្គាល់លើចំណុចនេះ ហើយខ្ញុំនឹងធ្វើការកែលម្អទៅតាមអនុសាសន៍ឲ្យបានត្រឹមត្រូវសម្រាប់ការអនុវត្តនាពេលខាងមុខ។

<u>ការអធិប្បាយបន្ថែមរបស់សវនករ</u> លោកប្រធានមន្ទីរបានទទួលស្គាល់នូវចំណុចខ្វះខាតខាងលើនេះ ហើយសន្យាថា នឹងធ្វើការត្រួតពិនិត្យមើលឡើងវិញ និងណែនាំដល់មន្ត្រីទទួលបន្ទុកដើម្បីអនុវត្តឲ្យបានល្អប្រសើរនាពេលខាងមុខទៀត។

## ៦ .សេចក្តីសន្និដ្ឋានរួម

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តមណ្ឌលគិរី រតនគិរី កំពង់ស្ពឺ និងរាជធានីភ្នំពេញ យកចិត្តទុកដាក់បំពេញការងារទៅតាមតួនាទី ភារកិច្ច ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំដែលបានកំណត់ ដោយព្យាយាមឲ្យសម្រេចបានលទ្ធផលទៅតាមការគ្រោងទុក។ ទន្ទឹមនឹងនេះ ក៏នៅមានការខ្វះចន្លោះមួយចំនួន ដែលសវនករផ្ទៃក្នុងបានកត់សម្គាល់ឃើញ៖

-មានភាពខ្វះចន្លោះក្នុងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលទ្ធផលការងារចុងក្រោយ

-ការរៀបចំឯកសារទូទាត់ មិនទាន់មានភាពពេញលេញល្អ

-ការអនុវត្តការងារមួយចំនួនមិនទាន់មានភាពអនុលោមទាំងស្រុង។

ចំណុចទាំងនេះអាចធ្វើឲ្យរាំងស្ទះខ្លះដល់កិច្ចខិតខំប្រឹងប្រែងលើកកម្ពស់តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងអភិបាលកិច្ចល្អរបស់មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្តទាំងនោះ បើទោះជាកត្តាទាំងនេះ វាមិនបានធ្វើឲ្យអាក់ខានដល់ដំណើរការចំបងរបស់មន្ទីរក៏ដោយ។ ប៉ុន្តែប្រសិនបើយឺតយ៉ាវក្នុងការអនុវត្តតាមអនុសាសន៍កែលម្អលើចំណុចខ្វះខាតទាំងនេះ ដោយការិយាល័យពាក់ព័ន្ធ ឬសវនដ្ឋានមិនអាចអនុវត្តបានតាមផែនការកែលម្អរបស់សវនករ នោះបច្ច័យនឹងអាចបន្តប៉ះពាល់ដល់ប្រសិទ្ធភាពរួមនៃកិច្ចប្រតិបត្តិការរបស់អង្គភាពទាំងមូល។

## ៧ .ផែនការសកម្មភាពកែលម្អ

សវនករបានផ្តល់ជូននូវផែនការសកម្មភាពកែលម្អ ទៅដល់បណ្តាសវនដ្ឋានដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តកែលម្អរាល់ចំណុចខ្វះខាត ជាពិសេសសវនករនឹងចុះតាមដានការអនុវត្តតាមអនុសាសន៍ឲ្យកាន់តែមានប្រសិទ្ធភាព ក្នុងការតាមដាន និងអនុវត្តការងារ។

ថ្ងៃពុធ ៧ រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០២០

**ប្រធាននាយកដ្ឋាន**

ពៅ្រជ្ញ សេដ្ឋា